ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២០០ ហិកតា ស្ថិតនៅភូមិកែបថ្មី និងភូមិទទឹងថ្ងៃ ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ធ្វើអនុបយោគផ្ទៃដីសាធារណៈរបស់រដ្ឋទំហំ ២០០ (ពីររយ) ហិកតា ស្ថិតនៅភូមិកែបថ្មី និងភូមិទទឹងថ្ងៃ ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ជាដីឯកជនរបស់រដ្ឋតាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ចុះបញ្ជីជាដីឯកជនរបស់រដ្ឋក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្តកំពតនូវផ្ទៃដី ទំហំ ៨០ (ប៉ែតសិប) ហិកតា និងផ្តល់កម្មសិទ្ធិឯកជន

ជូនក្រុមហ៊ុន IGB (CAMBODIA) Co., Ltd. ទំហំ ១២០ (មួយរយម្ភៃ) ហិកតា សម្រាប់អភិវឌ្ឍគម្រោងវិនិយោគបម្រើឱ្យវិស័យទេសចរណ៍ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៣០ អនក្រ.បក...ចុះថ្ងៃទី...៣១.....ខែ...ធ្នូ.......ឆ្នាំ២០២០




តារាងនិយាមការព្រំដី

Projection,UTM, Zone 48N

Datum,WGS,1984

| ID | E | N | ID | E | N |
|---|---|---|---|---|---|
| 1 | 405626.313 | 1166688.266 | 19 | 406515.769 | 1166766.184 |
| 2 | 405138.589 | 1166671.847 | 20 | 406175.903 | 1166706.812 |
| 3 | 404767.433 | 1166876.832 | 21 | 405676.187 | 1166689.948 |
| 4 | 404649.272 | 1167121.633 | 22 | 405126.494 | 1166621.408 |
| 5 | 404731.610 | 1167412.823 | 23 | 404729.324 | 1166840.760 |
| 6 | 404929.376 | 1167534.120 | 24 | 404595.917 | 1167117.149 |
| 7 | 405026.497 | 1167547.215 | 25 | 404688.822 | 1167445.235 |
| 8 | 405210.749 | 1167630.009 | 26 | 404912.233 | 1167582.261 |
| 9 | 405276.013 | 1167718.557 | 27 | 405012.623 | 1167595.796 |
| 10 | 405591.960 | 1167749.923 | 28 | 405178.286 | 1167670.238 |
| 11 | 405641.728 | 1167754.873 | 29 | 405248.953 | 1167766.117 |
| 12 | 406102.889 | 1167800.655 | 30 | 406195.515 | 1167860.096 |
| 13 | 406194.609 | 1167809.761 | 31 | 406477.942 | 1167821.752 |
| 14 | 406358.597 | 1167787.496 | 32 | 406592.919 | 1167759.268 |
| 15 | 406462.127 | 1167773.441 | 33 | 407114.698 | 1167303.560 |
| 16 | 406564.189 | 1167717.974 | 34 | 406878.891 | 1166986.718 |
| 17 | 407046.981 | 1167296.318 | 35 | 406536.708 | 1166719.085 |
| 18 | 406842.793 | 1167021.961 | 36 | 406181.073 | 1166656.958 |